Australian Government

Job Services Australia
people • skills • jobs

# Work Experience

## បទពិសោធន៍ការងារ (Work Experience) អាចផ្ដល់ឱកាសឱ្យលោកអ្នកពង្រីកជំនាញការងារ និងបើកឱកាសស្វែងរកការងាររបស់លោកអ្នក។

សកម្មភាព Work Experience អាចផ្ដល់ជូនលោកអ្នកនូវមធ្យោបាយជាក់ស្ដែងសម្រាប់ភ្ជាប់លោកអ្នកជាមួយសហគមន៍របស់លោកអ្នក និងដើម្បីបង្ហាញសមត្ថភាពរបស់លោកអ្នកចំពោះអនាគតនិយោជក។

បទពិសោធន៍ការងារនឹងជួយលោកអ្នកក្នុងការ៖

- អភិវឌ្ឍជំនាញការងាររបស់លោកអ្នកនៅក្នុងពេលធ្វើការ
- បង្ហាញសមត្ថភាពរបស់លោកអ្នកចំពោះអនាគតនិយោជក
- ទទួលបានឯកសារយោងស្ដីពីការងារ
- ជួបទំនាក់ទំនងការងារថ្មីៗ
- ចូលរួមក្នុងការបណ្ដុះបណ្ដាលហ្វឹកហ្វឺនដែលមានការរៀបចំ
- រក្សាទំនាក់ទំនងជាមួយកងកម្លាំងពលកម្ម

លោកអ្នកអាចចូលរួមក្នុងសកម្មភាព Work Experience នៅពេលណាក៏បាន។ ប្រសិនបើលោកអ្នកមិនមានការងារធ្វើរយៈពេល ១២ខែ លោកអ្នកប្រហែលជាត្រូវចូលរួមក្នុងសកម្មភាព Work Experience មួយ ឬច្រើនដែលនឹងជួយលោកអ្នកក្នុងការអភិវឌ្ឍជំនាញ និងដកបទពិសោធន៍ពីមជ្ឈដ្ឋានការងារ។ ស្ថាប័នផ្ដល់សេវាការងារអូស្ត្រាលី (Job Services Australia) របស់លោកអ្នកនឹងផ្ដល់ការណែនាំដល់លោកអ្នក នៅពេលលោកអ្នកត្រូវចាប់ផ្ដើមសកម្មភាព Work Experience ណាមួយ។

ប្រសិនបើលោកអ្នកមិនអាចចូលរួមក្នុងសកម្មភាពណាមួយ ក្នុងចំណោមសកម្មភាពទាំងនេះបានទេ លោកអ្នកប្រហែលជាអាចចូលរួមក្នុងកម្មវិធី ឬសេវាដើម្បីជួយឱ្យលោកអ្នកឆ្លងកាត់ឧបសគ្គដទៃទៀត ដែលរារាំងមិនឲ្យលោកអ្នកទទួលបានការងារ ដូចជាបញ្ហាសុខភាព ការគ្មានផ្ទះសម្បែង ឬជំនាញផ្ទាល់ខ្លួន។ ប្រសិនបើលោកអ្នកកំពុងចូលរួមជាមួយនឹងសេវាទាំងនេះ លោកអ្នកប្រហែលជាមិនចាំបាច់ចូលរួមសកម្មភាព Work Experience បន្ថែមទៀតទេ។

នៅក្នុង Work Experience លោកអ្នកអាចគួបបញ្ចូលសកម្មភាពជាច្រើន។ លោកអ្នកក៏ប្រហែលជាអាចចូលរួមផងដែរនៅពេលដែលសមរម្យបំផុតទៅនឹងកាតព្វកិច្ចដទៃទៀត របស់លោកអ្នក មានដូចជាការសិក្សា ការងារមិនពេញពេល ឬមិនទៀងទាត់ ឬបន្ទុកចិញ្ចឹមកូនជាដើម។

លោកអ្នកអាចធ្វើការជ្រើសរើសយកសកម្មភាពពីជម្រើសដែលមានជូនជាច្រើនយ៉ាង ក្នុងនោះរួមមាន ផ្នែកណាមួយនៃការងារជាក្រុមសម្រាប់សកម្មភាពជាក្រុម ឬសកម្មភាពរៀងៗខ្លួន តាមរយៈការដាក់ឲ្យធ្វើការនៅក្នុងសកម្មភាព Work Experience ជាមួយនឹងស្ថាប័នទទួលលោកអ្នកឲ្យដកពិសោធន៍ការងារ។

សកម្មភាពអាចមានរួមបញ្ចូល៖

- សកម្មភាព Work for the Dole (ដោយរួមទាំងសកម្មភាព Work for the Dole ពេញលេញ)។
- សកម្មភាពបរិស្ថាន Green Corps។
- ការសិក្សាមិនពេញពេល (តាមរយៈកម្មវិធីផ្ដល់កន្លែងបង្កើនផលិតភាព [Productivity Places Program] ) ឬការបណ្ដុះបណ្ដាលហ្វឹកហ្វឺនវិជ្ជាជីវៈដទៃទៀត ដែលមានផ្ដល់សញ្ញាបត្រ)។
- ការងារមិនពេញលេញ ឬមិនទៀងទាត់ដែលមានប្រាក់កម្រៃ។
- សកម្មភាពផ្ដល់កន្លែងដកស្រង់បទពិសោធការងារដោយគ្មានប្រាក់កម្រៃ (Unpaid Work Experience Placement)
- សកម្មភាពការងារស្ម័គ្រចិត្ត (Voluntary Work) ក្នុងសហគមន៍។
- ការងារមាន និងគ្មានប្រាក់កម្រៃក្នុងសហគ្រាសបម្រើសង្គម។
- សកម្មភាពកងកម្លាំងសម្រាប់គ្រោះរាំងស្ងួត (Drought Force)។
- កងកម្លាំងការពារដែលត្រៀមបម្រុង (Defence Force Reserves)
- កម្មវិធីការងារ ឬបណ្ដុះបណ្ដាលហ្វឹកហ្វឺនដែលគ្រប់គ្រងដោយរដ្ឋាភិបាលអូស្ត្រាលី ឬកម្មវិធី ឬសេវារដ្ឋាភិបាលតាមរដ្ឋ ឬដែនដី ដែលដោះស្រាយឧបសគ្គមិនពាក់ព័ន្ធនឹងវិជ្ជាជីវៈ (នៅពេលសមរម្យ)។
- ការផ្លាស់ប្ដូរទីលំនៅទៅតំបន់ដែលមានឱកាសការងារប្រសើរជាង តាមរយៈសកម្មភាពស្វែងរកការងារខ្លាំងក្លា។

លោកអ្នកនឹងជួបជាមួយស្ថាប័នផ្ដល់ Job Services Australia របស់លោកអ្នកដើម្បីពិភាក្សាអំពីជម្រើសនៃសកម្មភាពផ្សេងៗដែលមានក្នុងតំបន់របស់លោកអ្នក។ លោកអ្នកមានពេលរហូតដល់ ៦សប្ដាហ៍ បន្ទាប់ពីការជួបពិភាក្សានេះ ក្នុងការជ្រើសរើសសកម្មភាព Work Experience មួយ ឬសកម្មភាពគួបបញ្ចូលគ្នា ប្រសិនបើលោកអ្នកមិនជ្រើសរើសយកសកម្មភាពណាមួយទេនោះ ស្ថាប័នការងារអូស្ត្រាលីរបស់លោកអ្នកនឹងឱ្យលោកអ្នកចូលរួមក្នុងសកម្មភាព Work for the Dole ឬ Green Corps។ ប្រសិនបើលោកអ្នកពុំមានសិទ្ធិចូលរួមក្នុងសកម្មភាពទាំងនេះទេ លោកអ្នកនឹងត្រូវគេចាត់ឱ្យចូលទៅក្នុងសកម្មភាពផ្សេងទៀត។

## តើអ្នកណាអាចចូលរួមបាន?

អ្នកស្វែងរកការងារធ្វើដែលមានអាយុចន្លោះ ពី១៨ទៅ៤៩ឆ្នាំ ដែលបានបញ្ចប់ការចំណាយពេលផលាជាមួយស្ថាប័នផ្ដល់សេវា Job Services Australia ប្រហែលជា ១២ខែ ត្រូវចូលរួមក្នុង Work Experience Activity មួយ ឬគួបបញ្ចូលគ្នា ក្នុងអំឡុងពេល ២៦សប្ដាហ៍ សម្រាប់រាល់ការទទួលសេវារយៈពេល ១២ខែថែមទៀត ពីស្ថាប័នផ្ដល់ Job Services Australia។

លោកអ្នកមិនចាំបាច់ចូលរួមទេ ប្រសិនបើលោកអ្នក ៖

- ទទួលបានការលើកលែងពីតេស្តសកម្មភាព (Activity Test) ឬតម្រូវការចូលរួម។
- មានអាយុចន្លោះពី ១៥ទៅ១៧ឆ្នាំ។
- អ្នកទោសដែលបានទទួលការដោះលែងមុនកាលកំណត់។
- មានអាយុ ៥០ឆ្នាំ ឬលើសពីនេះ (លុះត្រាតែលោកអ្នកមានអាយុ ពី៥០ទៅ៥៩ឆ្នាំ ដែលបំពេញតាមតម្រូវការតេស្តសកម្មភាព (Activity Test) ពេញពេល ហើយស្ថាប័នផ្ដល់សេវារបស់លោកអ្នកពិចារណាឃើញថា លោកអ្នកអាចទទួលប្រយោជន៍ពីសកម្មភាពពេញលេញនៃ Work for the Dole )។

5FS09446JSA/khmer

ទោះជាយ៉ាងណាក្តី ក៏អ្នកស្វែងរកការងារធ្វើ ដែលមានស្ថាប័ន Job Services Australia និងទទួលបានជំនួយទ្រទ្រង់ប្រាក់ចំណូល អាចជ្រើសរើសចូលរួមដោយស្ម័គ្រក្នុងសកម្មភាព Work Experience ណាមួយ ដែលស្របតាមការព្រមព្រៀងជាមួយស្ថាប័ន Job Services Australia របស់ខ្លួន។

អ្នកស្វែងរកការងារធ្វើដែលត្រូវបំពេញសកម្មភាពខ្លាំងក្លា (Intensive Activity) ឬសកម្មភាពប្រតិបត្តិតាម (Compliance Activity) ណាមួយ គឺអាចធ្វើទៅបានដោយការចូលរួមក្នុងសកម្មភាព Work Experience។ ស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នកនឹងផ្តល់ការណែនាំដល់លោកអ្នក ប្រសិនបើលោកអ្នកត្រូវចូលរួមក្នុង Intensive Activity ឬ Compliance Activity។

## ភាតព្វកិច្ចរបស់លោកអ្នក

ប្រសិនបើលោកអ្នកទទួល Newstart ប្រាក់ឧបត្ថម្ភសម្រាប់យុវវ័យ (Youth Allowance) ឬប្រាក់ជំនួយសម្រាប់ចិញ្ចឹមកូន (Parenting Payment) ហើយមានការតម្រូវឲ្យលោកអ្នកចូលរួម លោកអ្នកនឹងត្រូវស្វែងរកការងារធ្វើ ហើយចូលរួមក្នុងសកម្មភាពទាំងឡាយណា ដែលអាចជួយឱ្យលោកអ្នកស្វែងរកការធ្វើបាន។

ស្ថាប័ន Job Services Australia របស់លោកអ្នកនឹងពិចារណាអំពីស្ថានភាពផ្ទាល់របស់លោកអ្នក ហើយចរចាអំពីសកម្មភាពសមស្របទាំងពួងដែលគេនឹងដាក់បញ្ចូលទៅក្នុង Employment Pathway Plan របស់លោកអ្នក។

ប្រសិនបើលោកអ្នកមិនអាចចូលរួមក្នុងសកម្មភាពទាំងនោះ លោកអ្នកគួរពិភាក្សាបញ្ហានេះជាមួយស្ថាប័ន Job Services Australia របស់លោកអ្នក។ ប្រសិនបើលោកអ្នកខកខានមិនបានអនុវត្តតាមសកម្មភាពដែលបានព្រមព្រៀងទេ បញ្ហាប៉ះពាល់ដល់ថវិកាគាំទ្រ ចំណូលរបស់លោកអ្នកអាចកើតមានឡើង។

## សិទ្ធិឯកជនរបស់លោកអ្នក

ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ត្រូវបានការពារដោយ *ច្បាប់ឯកជនឆ្នាំ១៩៨៨ (Privacy Act 1988)* ហើយព័ត៌មានអំពីលោកអ្នក អាចត្រូវបានការពារផងដែរដោយ *ច្បាប់ (រដ្ឋបាល) សន្តិសុខសង្គមឆ្នាំ១៩៩៩ (Social Security [Administration] Act 1999)* (ឧទាហរណ៍ ប្រសិនបើលោកអ្នកទទួលប្រាក់ជំនួយទ្រទ្រង់ប្រាក់ចំណូល)។ ព័ត៌មានរបស់លោកអ្នកអាចត្រូវស្ថាប័នផ្តល់ Job Services Australia ព្រមទាំងក្រសួងអប់រំការងារ និងទំនាក់ទំនងកន្លែងធ្វើការ [DEEWR], (Department of Education, Employment and Workplace Relations [DEEWR]) ប្រើប្រាស់រួមគ្នាជាមួយ Centrelink និងក្រសួង ក៏ដូចជាទីភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីផ្សេងៗទៀត ដើម្បីផ្តល់លទ្ធភាពឱ្យអង្គការទាំងនោះ ផ្តល់ជូនលោកអ្នកនូវសេវាដ៏សមស្របបំផុត ដើម្បីបំពេញតាមតម្រូវការរបស់លោកអ្នក។

ចំពោះព័ត៌មានបន្ថែមអំពីភាពឯកជនរបស់លោកអ្នក សូមសាកសួរស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នក DEEWR ឬបើកមើលវ៉ិបសាយថ៍ **privacy.gov.au** ។

## ការធានាផ្តល់ សេវារបស់យើងជូនលោកអ្នក

### ការធានាសេវា

លោកអ្នកនឹងទទួលបានសេវាការងាររៀបចំឡើងសម្រាប់រូបលោកអ្នកផ្ទាល់ដែលផ្តល់ដោយស្ថាប័នផ្តល់ Job Services Australia ។ សេវាទាំងនេះនឹងមានលក្ខណៈបត់បែនទៅតាមស្ថានភាព និងប្រវត្តិការងាររបស់លោកអ្នក។ ដើម្បីមើលពីការធានារបស់សេវាទាំងអស់នេះ សូមចូលទៅវ៉ិបសាយថ៍ **deewr.gov.au/jobservicesaustralia** ។

### ក្រមសីលធម៌វិជ្ជាជីវៈ

ស្ថាប័នផ្តល់ Job Services Australia ចុះកិច្ចសន្យាដើម្បីផ្តល់សេវាការងារដែលឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី និងបានយល់ព្រម ហើយប្តេជ្ញាប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈ ក្នុងការផ្តល់សេវាការងារនេះ។ ដើម្បីមើលក្រមសីលធម៌វិជ្ជាជីវៈ សូមចូលទៅវ៉ិបសាយថ៍ **deewr.gov.au/jobservicesaustralia**។

## សម្រាប់ព័ត៌មានបន្ថែម

**សូមទូរស័ព្ទទៅលេខ 13 17 64 ឬបើកមើលវ៉ិបសាយថ៍ deewr.gov.au/jobservicesaustralia ។**